# សាកលវិទ្យាល័យ អង្គរខេមរា

# ANGKOR KHEMARA UNIVERSITY

**មហាវិទ្យាល័យ**
College
**សិល្បៈ មនុស្សសាស្ត្រ និងភាសា**
Arts, Humanities and Languages

**ឯកទេស៖ អក្សរសាស្ត្រខ្មែរ**
Specialty: Khmer Literature

## កិច្ចការស្រាវជ្រាវ

### មុខវិជ្ជា: អក្សរសិល្ប៍សម័យទំនើប១៩៥៣-បច្ចុប្បន្ន

### ប្រធានបទ

### "សិក្សាអំពីបញ្ហាជីវភាពរស់នៅរបស់ប្រជាជនខ្មែរតាមរយៈអក្សរសិល្ប៍សម័យទំនើបក្នុងរឿងភូមិតិរច្ឆាន"

**បង្រៀនដោយ៖ អនុ. ផង់ តិរុណា**

**និស្សិតថ្នាក់បរិញ្ញាបត្រ**

**ក្រុមនិស្សិត ជំនាន់ទី១៤-១៥ ឆ្នាំទី៤ ឆមាសទី២ ស.អ.ខ ខេត្តពោធិ៍សាត់**

| | |
|---|---|
| ១- ប្រីយ រក្សា | ភេទ៖ ស្រី |
| ២- ណាង ស្រីនីត | ភេទ៖ ស្រី |
| ៣- ស៊ុំ សាម៉ាន | ភេទ៖ ស្រី |
| ៤- ចិន យ័ន | ភេទ៖ ប្រុស |
| ៥- ផន ឃួន | ភេទ៖ ប្រុស |
| ៥- ឌី ជីវ័ន្ត | ភេទ៖ ប្រុស |

**ឆ្នាំសិក្សា២០២៥ - ២០២៦**

# ឧទ្ទិសកថា

ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះ៖

- វិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់រូបដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិ មាតុ ភូមិ។
- វិញ្ញាណក្ខន្ធកវី បណ្ឌិត អ្នកនិពន្ធ អ្នកប្រាជ្ញខ្មែរគ្រប់ជំនាន់។ ដែលបានខិតខំថែរក្សាអក្សរសាស្ត្រ ជាតិឱ្យរីកចម្រើនគង់វង្សរហូតមកដល់សព្វថ្ងៃ។
- វិញ្ញាណក្ខន្ធសម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលព្រះអង្គបាន បន្សល់ស្នាដៃដ៏វិសេសវិសាល សម្រាប់កូនខ្មែរគ្រប់ជំនាន់នោះគឺ សៀវភៅវចនានុក្រមខ្មែរ។
- វិញ្ញាណក្ខន្ធនៃបុព្វការីជនរបស់ខ្ញុំទាំងអស់។

សូមជួយទ្រទ្រង់វិស័យអក្សរសាស្ត្រជាតិឱ្យកាន់តែរីកចម្រើនជានិច្ចនិរន្តរ៍។

# សេចក្តីថ្លែងអំណរគុណ

ទន្ទឹមនឹងការកកើតនូវស្នាដៃឡើងបានជាលទ្ធផលនេះខ្ញុំបាទសូមសម្តែងនូវអំណរគុណជាអនេកប្រការចំពោះ ៖

លោកឪពុក អ្នកម្តាយនៃខ្ញុំទាំងឡាយជាបុព្វាចារ្យនឹងជាព្រះអរហន្តដ៏ប្រសើររបស់ខ្ញុំបាទដែលលោកបានផ្តល់នៅកំណើត ហើយចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារធម៌។ ជានិច្ចកាលលោកតែងតែណែនាំ ចង់ឲ្យក្លាយជាគ្រាប់ពូជដ៏មានតម្លៃមួយ។

លោកគ្រូ អ្នកគ្រូទាំងអស់តាំងពីថ្នាក់បឋមសិក្សារហូតមកដែលអស់លោកបានបង្ហាត់បង្រៀនឲ្យខ្ញុំបាទនៅទ្រព្យសម្បត្តិដែលមិនអាចកាត់ថ្លៃបានពោលគឺចំណេះវិជ្ជា ព្រមទាំងសីលធម៌ សុជីវធម៌ក្នុងសង្គមធ្វើឲ្យ ក្លាយជាធនធានដ៏មានតម្លៃមួយសម្រាប់សង្គមជាតិ។

បណ្ឌិត **នូ ចាន់សុភី** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអង្គរខេមរា និងគណៈគ្រប់គ្រងនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ធ្វើឲ្យខ្ញុំបានទទួលបានចំណេះដឹងដ៏មានតម្លៃសម្រាប់ជួយខ្លួនឯង គ្រួសារ និងសង្គមជាតិបានមួយចំណែក។

សាស្ត្រាចារ្យក្នុងឯកទេសអក្សរសាស្ត្រខ្មែរនៃសាកលវិទ្យាល័យអង្គរខេមរាទាំងអស់ដែលបានខិតខំប្រិតប្រៀនតម្រែតម្រង់នៅមុខវិជ្ជាទាំងឡាយក្នុងជំនាញអក្សរសាស្ត្រខ្មែរញ៉ាំងឲ្យខ្ញុំបាទទទួលនូវចំណេះដឹងយ៉ាងស្រួចស្រាល់លើជំនាញរបស់ខ្ញុំ។ ជាពិសេសសូមអរគុណជាអនេក ចំពោះសាស្ត្រាចារ្យអនុ. **ផង់ តិរុណា** ដែលបង្រៀនលើមុខវិជ្ជាអក្សរសិល្ប៍១៩៥៣-បច្ចុប្បន្នដែលបានណែនាំកែតម្រូវលើការស្រាវជ្រាវមួយនេះ។

# មាតិកា


**១. សេចក្ដីផ្ដើម** ............................................................................................. ទំព័រ១

**២. ទិដ្ឋភាពប្រវត្តិ**.............................................................................................. ទំព័រ២

២.១ ប្រភព

២.២ ប្រភេទ

២.៣ ចលនា

២.៤ ឥទ្ធិពល

២.៥ សង្គមបរិយាកាស

២.៦ អ្នកនិពន្ធ

**៣. សង្ខេបរឿង** ................................................................................................ ទំព័រ៣

**៤.សិក្សាអំពីបញ្ហាជីវភាពរស់នៅរបស់ប្រជាជនខ្មែរ** ............................................. ទំព័រ៤

៤.១ ទំនាស់សង្គម

៤.២ បញ្ហាគម្លាតវណ្ណៈសង្គម

៤.៣ ជំនឿរបស់ប្រជាជន

៤.៤ ផ្នែកនយោបាយ

**៥.សេចក្ដីសន្និដ្ឋាន** .......................................................................................... **ទំព័រ៩**

## ១. សេចក្តីផ្តើម

ភូមិតិរច្ឆានព្រឹត្តិការណ៍ ១៨ មេសា ប៉ុន្តែគឺជារឿងពិត នៅដើមសតវត្សទី២០ នេះ។ ពុំមែនជារឿងយល់សប្តិ របស់អ្នកនិពន្ធទេប៉ុន្តែគឺជារឿងពិត នៅដើមសតវត្សទី២០នេះ។

ព្រឹត្តិការណ៍ ១៨ មេសា នឹងបង្ហាញលោកអ្នកអានជ្រាប អំពីចលនាបាតុកម្មមួយប្រឆាំងទល់នឹងអាណានិគមបារាំងសែស នៅឆ្នាំ ១៩២៥។ ចលនានេះ មានសភាពឃោរឃៅគួរឲ្យតក់ស្លុតក្រៃលែង ដែលបានផ្ទុះឡើងពីចំណោមកសិករខ្មែរសុទ្ធសាធ នៅភូមិក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ក្រោមការដឹកនាំរបស់អ្នកក្លាហានពីរនាក់ គឺឈ្មោះ ជួន និងឈ្មោះ នៅ ដែលមានដើមកំណើត និងទីលំនៅ នៅភូមិបន្ទាយអំពិល ឃុំព្រៃខ្មែរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ពួកបាតុករ បានសម្លាប់លោកបារាំងម្នាក់ ឈ្មោះបាដេស ដែលធ្វើជារេស៊ីដង់នៅខេត្តកំពង់ឆ្នាំង ហើយនិង អ្នកបកប្រែភាសាម្នាក់ទៀត ឈ្មោះ សួន ព្រមទាំងទាហានរក្សាស្រុកម្នាក់ ឈ្មោះ ឡាច ដែលបានទៅតាមបារាំង នៅពេលនោះ។

ព្រឹត្តិការណ៍ ១៨ មេសា ១៩២៥ របស់ប្រជាជនឃុំក្រាំងលាវ ជាព្រឹត្តិការណ៍មួយ បានទាក់ទាញចិត្តអ្នកនិពន្ធ ក្នុងការនិពន្ធស្នាដៃនេះ ដើម្បីដាស់សតិស្មារតីប្រជាជន ឲ្យនឹកឃើញជាប់ជានិច្ចនូវប្រវត្តិយ៉ាងឈឺចាប់ខ្លោចផ្សា ដែលពួកអាណានិគមបង្កឡើងនោះ។

រឿងភូមិតិរច្ឆាន ពិតជាបានទាញអារម្មណ៍ អ្នកអានឲ្យនឹកឃើញ ពីនឹមដែក របស់អាណានិគមបារាំង ដែលសង្កត់ប្រជាជនកម្ពុជា ជិតមួយសតវត្ស។ ទន្ទឹមនឹងនោះ ក៏បានបំផុសកំហឹងឈឺចាប់ដល់អ្នកអាន ពីទារុណកម្មដ៏សែនឃោរឃៅ របស់អាណានិគម បារាំង មកលើប្រជាជនស្លូតត្រង់កម្ពុជាយើង។ ការតស៊ូប្រឆាំងនឹងពួកត្រួតត្រាការចងកំហឹងឈឺចាប់នៃជនដែលត្រូវគេជិះជាន់ពួតផ្តុំបានជាកម្លាំងភ្ញាក់រឭក ស្នេហាជាតិ ដ៏មោះមុត ក្រោកឡើងតស៊ូរំដោះជាតិ។

ឆ្លងកាត់បទពិសោធជូរចត់ជាច្រើន នៅសម័យអាណានិគម អ្នកនិពន្ធបានពញ្ញាក់ស្មារតីប្រជាជនឲ្យប្រុងប្រយ័ត្នចំពោះនឹមថ្មីមួយទៀតរបស់ចក្រពត្តិអាមេរិក ដែលមានពិសពុលជាងអាណានិគមបារាំងទៅទៀត។ អ្នកនិពន្ធបានផ្សព្វផ្សាយរឿងនេះឡើង ក្នុងពេលចក្រពត្តិអាមេរិកកំពុងដាក់នឹមត្រួតត្រាលើប្រទេសកម្ពុជាយើង។

## ២. ទិដ្ឋភាពប្រវត្តិ

### ២.១ ប្រភព

អ្នកនិពន្ធបានប្រមូលឯកសារមកចងក្រងសរសេរនៅឆ្នាំ ១៩៦៤ ១៩៦៥ តែកាលៈទេសៈពេលនោះ ពុំទាន់អំណោយផលអាចបោះពុម្ពបាន។ អ្នកនិពន្ធរង់ចាំដល់ឆ្នាំ ១៩៧១ទើបបោះពុម្ពផ្សាយ។ ក្នុងការសរសេរតាក់តែងរឿងនេះឡើង អ្នកនិពន្ធបានដើរ ប្រមូលព័ត៌មានពីប្រជារាស្ត្រមានវ័យចាស់ដែលធ្លាប់ដឹងរឿងរ៉ាវនៅភូមិក្រាំងលាវ ហើយអ្នក និពន្ធបានខំស្រាវជ្រាវរកលិខិតនិងសេចក្តីសម្រេចផ្សេងៗពេលនោះមកធ្វើជាឯកសារសម្រាប់ សរសេរ។

### ២.២ ប្រភេទ

- ប្រភេទ ៖ជារឿងប្រលោមលោកបែបប្រវត្តិសាស្ត្រ។

### ២.៣ ចលនា

-ចលនា ៖អក្សរសិល្ប៍ខេមរនិយម។

### ២.៤ ឥទ្ធិពល

មានឥទ្ធិពលមនោគមវិជ្ជាជឿនលឿនក្នុងសម័យសង្គមរាស្ត្រនិយម ព្រោះដំណើរ រឿងបំផុសពីចលនាតស៊ូប្រឆាំងបរទេស ដើម្បីបូរណភាពទឹកដីរបស់ខ្លួន។

### ២.៥ សង្គមបរិយាកាស

សម័យកាលនៃរឿងនេះកើតឡើងនៅឆ្នាំ១៩២៥ ក្រោយការច្រូតកាត់ និងប្រទេសជាតិស្ថិតនៅក្រោមអាណានិគមបារាំងដែលប្រើអំណាចត្រួតត្រាមកលើប្រជាជន ខ្មែរ។ ទង្វើនេះបានធ្វើឲ្យមានចលនាប្រជាជនក្រោកឡើង ប្រឆាំងនឹងពួកបារាំងស្ទើរគ្រប់ទី កន្លែង ជាពិសេសព្រឹត្តិការណ៍ថ្ងៃទី១៨ មេសា ឆ្នាំ១៩២៥។

### ២.៦ អ្នកនិពន្ធ

-លោកឌឹក គាម និង ឡឺក អំ

## ៣. សង្ខេបរឿង

សង្គ្រាមលោកលើកទីមួយបានផ្ទុះឡើងក្នុងឆ្នាំ ១៩១៤ ដល់១៩១៩ ដែលប្រទេសកម្ពុជាស្ថិតនៅក្រោមនឹមអាណានិគមបារាំង ប្រជារាស្ត្រខ្មែររងទុក្ខវេទនាត្រូវពួកអាណានិគមកេណ្ឌឲ្យទៅច្បាំងប្រឆាំងនឹងពួកផាស៊ីសអាឡឺម៉ង់។ ទន្ទឹមនឹងនោះការឡើងថ្លៃពន្ធដារក៏កាន់តែកើនឡើងជារៀងរាល់ខែ ធ្វើឲ្យប្រជារាស្ត្រមានការ ក្តៅក្រហាយយ៉ាងខ្លាំង។ ប្រជារាស្ត្រនៅស្រុក មុខកំពូលចំនួន ៣០០០ នាក់បានធ្វើបាតុកម្ម ធ្វើញត្តិសុំឲ្យស្តេចស៊ីសុវត្ថិ ជួយបន្ធូរបន្ថយ ដូចជាមានរន្ទះបាញ់ចេតិយព្រះកែវមរកតនិងផ្កាយដុះកន្ទុយជាដើម។ នៅខេត្តកំពង់ឆ្នាំងក៏ ដូចជាខេត្តដទៃៗទៀតដែរ ប្រាសប្រពន្ធកូន។ នាងពុំដែលជាប្រពន្ធសុវណ្ណត្រូវស្លាប់ដោយសារខ្វះថវិការព្យាបាលជម្ងឺ។ អំពីបញ្ហាពន្ធដារនេះ។ សូម្បីតែធម្មជាតិក៏មាន ការក្តៅក្រហាយពុះកញ្ជ្រោលខ្លាំងដែរ ប្រជារាស្ត្រមានជីវភាពលំបាកលំបិនធ្វើឲ្យគ្រួសារមួយត្រូវព្រាត់ ចំណែកសុវណ្ណលំបាកក្នុងការ ថែទាំកូនតូចផងក៏ទទួលនាងតន់ធ្វើជាភរិយាដោយ មិនបានរៀប ការតាម ប្រពៃណីជាតិរបស់ខ្លួន។

ប្រជាជននៅភូមិក្រាំងលាវមានសម្លាញ់ពីរនាក់ឈ្មោះដូននិង នៅ បានរៀបចំគម្រោងការសម្លាប់រ៉េស៊ីដង់បារដេសដែលអនុវត្តអំពើយង់ឃ្នងព្រៃផ្សៃយង់ឃ្នង នៅពេលដែលពួកវាចុះទារពន្ធដារ។ ចលនារបស់ដូននិងនៅក៏ មានការចូលរួមពី ក្រុមអ្នកក្លាហានចំនួន ២០ នាក់ទៀត។

នៅភូមិដើមអំពិល មេឃុំប៉ាល់បានក្តាប់ពីរបាយការណ៍ជីវភាពរស់នៅរបស់ប្រជារាស្ត្រក្នុងភូមិគួបផ្សំនឹងការលំបាកក្នុងការទារពន្ធដារក៏សុំថ្នាក់លើលាលែងដើម្បីយករួចខ្លួន។ រ៉េស៊ីដង់បារដេសបានចេញទារពន្ធដារដោយខ្លួនឯង។ លុះដល់ថ្ងៃទី១៨ មេសា ១៩២៥ ការទារពន្ធដារមកដល់ភូមិក្រាំងលាវដែលដឹកនាំដោយរ៉េស៊ីដង់បារដេស កងរក្សាសន្តិសុខ ឈ្មោះឡាចនិងអ្នកជាំស្លឈ្មោះបោយពេលនោះបាដេសមានទំនាស់ជាមួយនាងនីនាងប៊ី។ ក្នុងសភាពការណ៍នេះជាឱកាសមួយដែលធ្វើឲ្យអ្នកក្លាហានហ៊ានចេញប្រយុទ្ធសម្លាប់រ៉េស៊ីដង់ បារដេសដោយឥតញញើតដៃ។ ក្នុងនោះនៅសល់តែអ្នកជាំស្លម្នាក់ ដែលរត់គេចខ្លួនហើយនាំ ដំណឹងនោះទៅរាយការណ៍នៅក្រុងកំពង់ឆ្នាំង។ ក្រោយសម្លាប់បារដេសនិង សហការីរួចមក ក្រុមអ្នកក្លាហានមានបំណងចេញទៅក្រុងកំពង់ឆ្នាំងទៀតប៉ុន្តែត្រូវកងទ័ពបារាំងពួនបាញ់ស្នា ក់បានស្លាប់ខ្លះ រត់ចូលព្រៃនៅក្នុងភូមិត្រពាំងស្រែ។ អ្នកក្លាហានត្រូវបាន គេបាញ់ស្លាប់ ក្នុងនោះមាននៅរីឯដូនត្រូវគេចាប់ខ្លួនដាក់គុកនៅកោះត្រឡាច ចំណែកឯ ប្រជាជន ត្រូវរត់ ចោលភូមិឋានទៅរស់នៅក្នុងព្រៃ។ រឿងសម្លាប់បារដេសធ្វើឲ្យមានប្រតិកម្មយ៉ាងខ្លាំងពីសំណាក់កុង្សីសេនាបតីអាណានិគមបារាំង។ ព្រះបាទស៊ីសុវត្ថិបានចេញសេចក្តី ប្រកាសមួយ ឲ្យប្តូរឈ្មោះពីភូមិក្រាំងលាវទៅជា ភូមិតិរច្ឆានវិញអស់រយៈពេលយ៉ាងតិច១០ឆ្នាំ

ព្រមទាំង ឲ្យសាងសង់ចេតិយព្រះកែវមរកតនិងធ្វើបុណ្យនៅថ្ងៃទី១៨ មេសា ជារៀងរាល់ឆ្នាំ។ ជាទីបញ្ចប់ ទាហានបានកៀរអ្នកស្រុកឲ្យមករស់នៅក្នុងភូមិរបស់ខ្លួនវិញ។ចំណែកសុវណ្ណ និងនាងតន់ក៏បានមករួមរស់រួមសុខ ជាមួយគ្នារៀងមកហើយអ្នកខ្លះទៀតក៏បានវិលមកជួបជុំប្រពន្ធកូនវិញដែរ។

## ៤.សិក្សាអំពីបញ្ហាជីវភាពរស់នៅរបស់ប្រជាជនខ្មែរ

### ៤.១ ទំនាស់សង្គម

#### ក.ទំនាស់រវាងអាណានិគមបារាំង និងប្រជាជនខ្មែរ

ទំនាស់នេះកើតចេញពីការប៉ះទង្គិចគ្នារវាងការចង់ត្រួតត្រាផ្តាច់ការរបស់បរទេស(បារាំង) និងការចង់បានសេរីភាពរបស់រាស្ត្រខ្មែរ។ ពួកបារាំងបានដាក់ច្បាប់តឹងតែង និងបង្ខំឱ្យខ្មែរស្តាប់បង្គាប់ដោយគ្មានលក្ខខណ្ឌសម្រាប់តវ៉ាអ្វីទាំងអស់។ អ្វីដែលធ្វើឱ្យទំនាស់នេះឈានដល់កម្រិតមួយដែលមានការប្រើអំពើហិង្សា គឺការទារពន្ធដារហួសហេតុក្នុងពេលដែលរាស្ត្រកំពុងក្រីក្រ និងការប្រមាថមើលងាយរាស្ត្រថាជា "សត្វធាតុ"។ ការជិះជាន់ផ្នែកសេដ្ឋកិច្ច និងការជាន់ឈ្លីកិត្តិយសជាតិបែបនេះធ្វើឱ្យប្រជាជនឈឺចាប់យ៉ាងខ្លាំង រហូតដល់មិនអាចទ្រាំរស់នៅក្រោមការត្រួតត្រារបស់បារាំងតទៅទៀតបានធ្វើឲ្យមានការរើបម្រាស់ដើម្បីទាមទារសេរីភាពត្រឡប់មកវិញ។

#### ខ.ទំនាស់រវាងអាជ្ញាធរខ្មែរ និងប្រជាជនខ្មែរ

ទំនាស់នេះឆ្លុះបញ្ចាំងពីការបែកបាក់ផ្ទៃក្នុងរវាងខ្មែរនិងខ្មែរ ដោយសារតែអំណាច និងបុណ្យស័ក្តិ។ មន្ត្រីខ្មែរមួយចំនួន មិនបានឈរខាងរាស្ត្រឯងឡើយ តែបែរជាសុខចិត្តធ្វើជាអាយ៉ងបម្រើបារាំងដើម្បីយកចិត្តពួកបារាំង សម្រាប់បម្រើតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ។ ពួកអាជ្ញាធរទាំងនោះបានប្រើអំណាចសង្កត់សង្កិន និងធ្វើបាបរាស្ត្រស្លូតត្រង់យ៉ាងសាហាវឃោរឃៅ ត្បូយ៉ាងដូចជាការវាយដំ ឃុំឃាំង នៅពេលគ្មានលុយសម្រាប់បង់ពន្ធជាដើម។ នៅពេលមន្ត្រីខ្មែរមើលរំលងទុក្ខសោករបស់រាស្ត្រ ហើយជួយជម្រុញការជិះជាន់បន្ថែម វាក៏បង្កើតជាកំហឹងវណ្ណៈ ដែលធ្វើឱ្យរាស្ត្រលែងមានទំនុកចិត្តលើអាជ្ញាធរជាតិខ្លួនឯង។

#### គ. ការតស៊ូរើបម្រាស់របស់ប្រជាជនពីការត្រួតត្រាផ្តាច់ការរបស់បារាំង

ចំណុចដែលនាំឲ្យផ្ទុះមានជាការតស៊ូប្រឆាំងកើតចេញពីការអត់ធ្មត់ដល់ទីបញ្ចប់របស់ប្រជាជន។ នៅពេលប្រជាជនសុំឲ្យមានការយោគយល់រឿងពន្ធដារ អាជ្ញាធរមិនត្រឹមតែមិនស្តាប់ប៉ុណ្ណោះទេ តែបែរជាប្រើហិង្សាមកលើអ្នកភូមិទៅវិញ ពួកគេក៏គ្មានផ្លូវជ្រើសរើសក្រៅពីការ

ងើបឡើងតស៊ូឡើយ។ ការរួមកម្លាំងសម្លាប់លោករេស៊ីដង់បាដេស គឺជាសកម្មភាពក្លាហានដើម្បីរំដោះខ្លួនពីនឹមអាណានិគម និងការពារសេចក្តីថ្លៃថ្នូររបស់ប្រជាជននៅភូមិក្រាំងលាវ ក៏ដូចជាប្រជាជនខ្មែរទាំងអស់។ ការតស៊ូនេះបង្ហាញថា ទោះប្រើអាវុធសាមញ្ញ (ដំបង កាំបិត ផ្គាក់) ក៏កម្លាំងសាមគ្គីរបស់រាស្ត្រអាចឈ្នះលើអំណាចអយុត្តិធម៌បានដែរ។

## ៤.២ បញ្ហាគម្លាតវណ្ណៈសង្គម

បញ្ហាគម្លាតវណ្ណៈសង្គម គឺជាធាតុសំខាន់មួយដែលអ្នកនិពន្ធបានរៀបរាយយ៉ាងច្បាស់តាមរយៈការបង្ហាញពី ភាពផ្ទុយគ្នាខ្លាំង រវាងវណ្ណៈផ្សេងៗ៖

### ក. វណ្ណៈអាណានិគមបារាំង និងអាយ៉ងខ្មែរ (ថ្នាក់ខ្ពស់)

- រួមមាន រេស៊ីដង់បារាំង (លោកបារដេស ឬបាដេស) និងមន្ត្រីអាយ៉ងខ្មែរ (របបសក្តិភូមិ មន្ត្រីអាយ៉ាង)។
- ពួកគេមានអំណាចពេញលេញ រស់នៅក្នុងភាពប្រណិត ប្រើអំណាចជិះជាន់ កេងប្រវ័ញ្ច និងយកពន្ធដារខ្ពស់ៗពីប្រជាជន។ ពួកគេមើលឃើញប្រជាជនខ្មែរជា «ពលករ» ឬ "ជនស្លូតត្រង់" ដែលត្រូវគេបង្ខំធ្វើការ និងគោរព។

ឧទាហរណ៍៖ ការដំឡើងពន្ធដារ ការចាប់ខ្លួន ការប្រើអំពើហិង្សា ដើម្បីបង្ខំឲ្យប្រជាជនបង់ពន្ធ ឬធ្វើការ។ នេះបង្ហាញពី គម្លាតអំណាច និងសេដ្ឋកិច្ច ដ៏ធំ។

### ខ. វណ្ណៈពលករ និងកសិករ (ថ្នាក់ក្រោម)

- រួមមាន ប្រជាជនធម្មតា កសិករ និងគ្រួសារក្រីក្រ ដូចជាតួអង្គដូចជា ជួន នៅ សុវណ្ណ នាងតន់ ជាដើម។
- ពួកគេរស់នៅក្នុងភាពក្រីក្រ រងទុក្ខវេទនា រងគ្រោះរាំងស្ងួត និងការកេងប្រវ័ញ្ច។ ពន្ធដារកើនឡើងធ្វើឲ្យជីវភាពកាន់តែលំបាក។
- គម្លាតនេះមិនត្រឹមតែជាសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែនៅតែជា គម្លាតសង្គម និងមនុស្សធម៌ផងដែរ (មួយភាគីមានអំណាច មួយភាគីត្រូវគេជិះជាន់)។

របៀបដែលគម្លាតវណ្ណៈនាំមកនូវជម្លោះ៖

- ការក្រោកឡើងប្រឆាំង៖ គម្លាតវណ្ណៈដ៏ធំនេះ បានបង្កើតកំហឹង និងការតស៊ូ។ តួអង្គដូចជា ជួន និង នៅ រួមជាមួយប្រជាជនក្លាហានប្រហែល ២០ នាក់ បានរៀបចំផែនការសម្លាប់លោក បារដេស និងសហការី នៅពេលដែលពួកគេចុះទារពន្ធ។ នេះគឺជាការវាយបកពីវណ្ណៈក្រោម ទៅលើវណ្ណៈខ្ពស់។
- ផលវិបាក៖ ក្រោយពីព្រឹត្តិការណ៍នេះ មានការស្លាប់ ការរត់ចូលព្រៃ ការចាប់ខ្លួន (ដូចជាជួន ត្រូវដាក់គុកនៅកោះត្រឡាច) និងការប្តូរឈ្មោះភូមិជា "តិរច្ឆាន" (ដើម្បីបន្ទាបប្រជាជន)។
- រឿងនេះបង្ហាញថា គម្លាតវណ្ណៈមិនត្រឹមតែនាំមកនូវទុក្ខវេទនា ប៉ុណ្ណោះទេ ប៉ុន្តែនៅតែជាកម្លាំងជំរុញឲ្យមានចលនាស្នេហាជាតិ និងការតស៊ូប្រឆាំងអាណានិគម។

## ៤.៣ ជំនឿរបស់ប្រជាជន

តាមរយៈរឿងភូមិតិរច្ឆាន អ្នកនិពន្ធបានរំលេចបង្ហាញឱ្យឃើញអំពីទិដ្ឋភាពនៃជំនឿរបស់ប្រជាជនទៅលើកម្លាំងអរូបីសឹងតែទាំងអស់ ដូចជា៖

### ក.ជំនឿលើបារមីសក្តិសិទ្ធិ

កាលគ្រាដែលបារាំងរើសទាហានបានល្មមគ្រប់ចំនួន ដើម្បីទៅជួយច្បាំងជា មួយនឹងបារាំងតទល់នឹងសង្គ្រាមអាឡឺម៉ង់ នាយទាហានបាននាំគ្នាស្ម័គ្រចិត្តទៅនៅ ក្នុងវៃវព្រះកែវមរកត ហើយនឹងហាត់វិធីយុទ្ធសាស្ត្រខ្លះផង។ ដោយភាពក្រអើតក្រទមមានចិត្តក្លៀវក្លាជាដើម រហូតលែងដឹងលែងស្គាល់លែងគោរពទំនៀមទម្លាប់ខ្មែរព្រោះតែអ្នកខ្លះនាំគ្នាស្រែកហ៊ោឡែឡ ធ្វើឫកវាងជាដើម ក៏បណ្តាលឱ្យទាហានខ្លះ ទៅជាចុះអាចម៍ ឈឺពោះ គ្រុនញាក់ញ័រ ព្រោះតែបំពានទីសក្តិសិទ្ធិ ទីអារាមដែលជាទី គោរពបូជា។ ក្រោយមកដោយមានរៀបចំកិច្ចពិធីសុំខមាលទោសចំពោះទង្វើផ្តាំផ្តងទាំងឡាយរបស់ខ្លួន ទាហានទាំងនោះក៏បានធូរស្រាល ជាបាត់នូវអាការៈអស់ទាំង នោះវិញទៅ។

### ខ.ជំនឿលើអ្នកតា

អ្នកតា គឺជាព្រលឹងនៃបុព្វជនដែលខ្លាំងពូកែ ហើយតាមជំនឿរបស់ខ្មែរ ក្រោយពេលអ្នកទាំងនោះស្លាប់ទៅ ព្រលឹងនោះនៅតែតាមថែរក្សាការពារអ្នកស្រុក ភូមិ ឬអ្នកជំនាន់ក្រោយៗទៀតជាបន្ត។ នៅក្នុងរឿងភូមិតិរច្ឆាន អ្នកនិពន្ធបានលើក និយាយអំពីការបន់ស្រន់សុំពរ និងការរក្សាថៃពីអ្នកតាដងកើ ពីសំណាក់ស្រីៗជាគូ សង្សារនឹងនាយទាហានដែលខ្មែរដែលចេញទៅច្បាំង ដោយលួចនិយាយនឹងអ្នកតា ដងកើថា "សូមលោកតាជួយមើលសង្សារ កុំឱ្យបាត់មត៌កនៅស្រុកបារាំង"។

### គ.ជំនឿលើអព្ភូតហេតុផ្សេងៗ

ក្រៅពីជឿលើកម្លាំងក្រៅខ្លួនផ្សេងៗ ដូចយ៉ាងជំនឿលើអ្នកតាជាដើម ប្រជាជនខ្មែរនៅមានជំនឿទៅលើអព្ភូតហេតុនៃធម្មជាតិផងដែរ។ នៅក្នុងរឿងអ្នកនិពន្ធក៏ បានលើកនិយាយអំពីជំនឿនេះដែរ ដូចយ៉ាងជំនឿលើរន្ទះបាញ់ចេតិយ៍ព្រះវិហារព្រះ កែវមរកតខាងត្បូង។

ក្នុងរឿងអ្នកនិពន្ធបានពិពណ៌នាថាៈ "បន្ទាប់ពីតំណែង និងការទារពន្ធ តំលើងពន្ធ នាម៉ឺនប្រជារាស្ត្រតាំងចាប់មានក្តៅចិត្តបន្តិចម្តងៗ ជាហេតុនាំឱ្យមានកើត ហេតុភេទខ្លះ។ បារាំងធ្វើឱ្យខ្មែរក្តៅក្រហាយ តាំងពីប្រជារាស្ត្រ នាម៉ឺន សង្ឃ ដូចនេះ ហើយបានជានៅថ្ងៃទិ ១៣ ខែតុលា ១៩២១ វេលាយប់នៅលើផ្ទៃអាកាសស្រាប់តែមានពពកប្រមូលផ្តុំគ្នាឡើងខ្មៅ ហើយមានផ្គរផ្លេកបន្ទោររន្ទះធុងធាំង ហាក់ដូចជា សន្មតគ្នាទុកជាមុន។ អ្នកស្រុកភិតភ័យអោបកូនថៅដោយសារខ្លាចស្នូររន្ទះ។ នៅវេលាម៉ោង ៩យប់ស្រាប់តែមានផ្លេកបន្ទោរ ភ្លែតដូចជាគេពុះមេឃ ហើយបន្តិចមក ស្នូរស្ទើរតែកក្រើកធរណី។ មិនយូរប៉ុន្មានសំលេងពីមាត់មួយទៅមាត់មួយ រន្ទះ បាញ់ចេតិយ៍ព្រះវិហារព្រះកែវមរកតខាងត្បូង ហេតុភេទនេះ ធ្វើឱ្យប្រជារាស្ត្រ នាម៉ឺន មានចិត្តស្រពោន ព្រោះតាមជំនឿថានឹងមានកើតចលាចល ឬមានកើតទុរភិក្សក្នុងស្រុក"។

មួយទៀត ក្នុងប្រព័ន្ធជំនឿខ្មែរ មនុស្សខ្មែរមានជំនឿយ៉ាងមុះមុតទៅលើ "ផ្កាយដុះកន្ទុយ" ដែលជាបាតុភូតិធម្មជាតិមួយ ដ្បិតតាមជំនឿខ្មែរតាំងពីបុរាណ។

កាលមក ប្រជាជនខ្មែរតែងកត់ចំណាំថា បើកាលណាកើតមានផ្កាយដុះកន្ទុយ ស្រុកនឹងមានកើតហេតុភេទមិនល្អ ជាពិសេសកើតមានសង្គ្រាម និងចលាចលជាដើមក្នុងស្រុកពុំខានឡើយ។

### ឃ.ជំនឿទៅលើទេវតា

មនុស្សខ្មែរមានការគោរពជឿច្រើនណាស់ ដោយគេជឿថា អ្វីៗទាំងអស់សុទ្ធ តែមានអ្នកកាន់ អ្នកថែរក្សា ឬអ្នកគ្រប់គ្រង ដូចយ៉ាងទឹកភ្លៀងនេះជាដើម។ នៅក្នុងរឿង អ្នកនិពន្ធបានរំលេចបញ្ជាក់ត្រង់ចំណុចនេះថា "រីឯអ្នកស្រុក ដែលរស់នៅក្នុង ភូមិភាគឆ្ងាយពីទន្លេ ហើយដែលពឹងផ្អែកតែលើទឹកភ្លៀងនោះ ច្រើនមានជីវភាពមិន នឹងនំ គឺជួនកាលតឹង ជួនកាលធូរ ស្រេចហើយតែទេវតាដាក់ទានភ្លៀងឱ្យ ឬមិនដាក់ ឱ្យប៉ុណ្ណោះ"។

### ង. សាសនា

តាមរយៈដំណើររឿងនាំឱ្យយើងទាញសន្និដ្ឋានបានថា ប្រជាជនខ្មែរគោរព ប្រណិបតន៍ព្រះពុទ្ធសាសនា ដូចដែលក្នុងរឿងបានលើកបង្ហាញពីសកម្មភាពមួយ ចំនួនដូចជា៖

- ក្នុងពិធីអបអរបុណ្យទានអ្វីមួយ ឬពិធីជូនដំណើរអ្នកស្លាប់គេតែងតែធ្វើតាម តម្រាយផ្លូវព្រះពុទ្ធសាសនា ដូចយ៉ាងនៅពេលដែលបារាំងច្បាំងឈ្នះអាឡឺម៉ង់ លោកបូផ្លាំងបានចាត់ឱ្យនិមន្តព្រះសង្ឃ ៥០០អង្គ មកសូត្រធម៌ ហើយនឹងមានធម្មកថិកសម្តែងធម៌ទេសនាទៀតផង។
- គ្រាដែលមានមនុស្សស្លាប់គេតែងធ្វើកិច្ចពិធីបុណ្យតាមបែបព្រះពុទ្ធសាសនា ដូចជាពេលនាងតុំស្លាប់ អ្នកភូមិបានចូលរួមចាប់កុសល ហើយសុវណ្ណក៏បានធ្វើបុណ្យបូជាសពប្រពន្ធគាត់ជាស្រេច។
- គ្រាដែលក្រុមបាតុករវាយសម្លាប់លោកបាដេស ដេកស្តូកស្តឹង ប៉ាល់ មេឃុំក្រាំងលាវ ដែលគាត់ជាអ្នកធម៌ គាត់បានឱ្យធម៌ឮសូរ "ពុទ្ធោ ធម្មោ សង្ឃោ" បួន ដប់ចប់ រួចផ្តុំបញ្ចូលព្រះធម៌ទៅក្នុងត្រចៀកលោកបាដេស ហាក់ដូចជាមានចិត្តចង់ឱ្យលោកនេះ ខិតខំប្រមូលអារម្មណ៍មុននឹងដាច់ខ្យល់ស្លាប់ ដើម្បីអាចនឹកដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមទំនៀមប្រពៃណីខ្មែរ។
- តាមទំនៀមរបស់មនុស្សខ្មែរ កាលណាបុរសឬស្ត្រីមានវ័យចំណាស់បន្តិចទៅ តែងតែប្រកាន់យកសីលទានដាក់ខ្លួនតាមលំអានទ្រឹស្តីព្រះពុទ្ធសាសនា ដូចសំដី តាប៉ាល់មានប្រសាសន៍ថា " ណា មួយខ្លួនកាន់តែចាស់ជរាទៅហើយ មិនបានកាន់សីលប្រាំចាំសីលប្រាំបីនឹងគេ"។
- ក្នុងកិច្ចពិធីធ្វើបុណ្យរំលឹកដល់វិញ្ញាណក្ខ័ន្ធនៃអ្នកដែលស្លាប់ទៅ ប្រជាជនខ្មែរតែងនិមន្តព្រះសង្ឃមកសូត្រមន្ត ដារ ឆាន់ ព្រមទាំងមានការសម្តែងធម៌ទេសនា សូត្រធម៌បង្សុល ប្រគេនទេយ្យធម្មជាដើម។
- ក្នុងការរក្សា ឬតម្កល់អដ្ឋិធាតុនៃអ្នកស្លាប់ប្រជាជនខ្មែរតែងតែរៀបចំកសាងចេតិយ៍មួយនៅតាមទីវត្តអារាម ឬក្បែរភូមិឋាន។ ក្នុងរឿងនេះ អ្នកនិពន្ធក៏បានលើ និយាយពីព្រះរាជប្រកាសមួយចេញឱ្យសង់ចេតិយ៍និងធ្វើបុណ្យសុំខមាលទោសសពលោកបាដេសនៅក្រាំងលាវ។

## ៤.៤ ផ្នែកនយោបាយ

ប្រទេសកម្ពុជាសម័យនោះស្ថិតក្រោមអាណានិគមបារាំង។គឺបារាំងគ្រប់គ្រងលើគ្រប់វិស័យនៃស្ថាប័នរដ្ឋទាំងអស់។ហើយប្រជាជនខ្មែរត្រូវបានក្លាយទៅជាឧបករណ៍ដាច់ថ្លៃរបស់បារាំងដោយអំណាចរបស់បារាំងបានធ្វើឲ្យមានផលលំបាកដល់ប្រជាជនខ្មែរ។ធ្វើឲ្យខ្មែរទទួលរកសម្លាធ។ក្នុងការទាពន្ធដារលើសកម្រិតហើយក៏បានចេះឥទ្ធិពលដល់ប្រជាជនខ្មែរធ្វើឲ្យប្រជាជនខ្មែរគ្មានចរិតមនុស្សធម៌សីលធម៌ជាខ្មែរវង្វេងលេងស្គាល់ជាតិប្រព្រឹត្តអំពើឃោរឃៅដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន។

ក្នុងស្ថានភាពដ៏លំបាកធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ខ្មែររួមមានវិស័យផ្សេងៗដូចជាៈ

### ក. វិស័យសេដ្ឋកិច្ច

វិស័យសេដ្ឋកិច្ចសម័យនោះមានលក្ខណៈទន់ខ្សោយព្រោះប្រាក់ចំណូលពន្ធដាររបស់រដ្ឋគឺបម្រើឲ្យតែបរទេសប្រជាជនគ្រប់គ្រួសារត្រូវចំណាយឲ្យពន្ធទៅលើបារាំងអស់បើពុំនោះទេនឹងត្រូវមានទោសក្នុងការគេចវេសមិនព្រមបង់ពន្ធ។

### គ.វិស័យកសិកម្ម

ប្រជាជនប្រកបការងារធ្វើស្រែចំការនិងដាំដំណាំបន្តិចបន្តួចប៉ុណ្ណោះដូចជាដាំឈូកឪឡឹកនេសាទនិងឡើងត្នោតជាដើម។

### ឃ.និស្ស័យពាណិជ្ជកម្ម

ជាក់ស្តែងយើងឃើញថាមានការលក់ដូរនៅទីផ្សារដូចជាសុវណ្ណនិងប៊ុតយកក្អមឆ្នាំងទៅលក់បន្ថែមមុខរបរទៀតសម្រាប់ចិញ្ចឹមជីវិត។

## ៥. សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្នាដៃអក្សរសិល្ប៍រឿងខាងលើ រួចមកយើងឃើញថា ក្នុងរឿងភូមិតិរច្ឆានពិតជាមានតម្លៃអប់រំទាំងផ្នែកអត្ថរូប អត្ថរស អត្ថន័យ និងរួមផ្សំជាមួយសិល្បៈប្រកបដោយភាពទាក់ទាញតាំងពីដើមរឿងរហូតដល់បញ្ចប់រឿង។ ហើយនៅក្នុងរឿងនេះដែរអ្នកនិពន្ធបានបង្ហាញពីតម្លៃអប់រំជាច្រើនសម្រាប់កូនចៅគ្រប់ជំនាន់ មានដូចជា ការគោរពប្រពៃណី ការរស់នៅ ការតស៊ូពុះពារពីភាពអយុត្តិធម៌ និងចងចាំភាពឈឺចាប់នៅក្នុងសាច់រឿង មានភាពក្លាហានដើម្បីរកភាព

សុខសាន្តឲ្យប្រទេសជាតិទាំងនេះជាតថភាពមួយដែលឆ្លុះបញ្ចាំងឱ្យឃើញពីសង្គមខ្មែរយើងនាសម័យនោះ។

## ៦. ឯកសារយោង

– ដកស្រង់ចេញ *"សមាគមអ្នកអក្សរសិល្ប៍កម្ពុជា"*។

សូមអរគុណ!